សន្លឹកឆ្នោតផ្លូវការរបស់ខោនធី Fresno និងសម្ភារៈបោះឆ្នោត ត្រូវបានបោះពុម្ពជាភាសាអង់គ្លេស និងភាសាអេស្ប៉ាញ ហើយមានចែកជូននៅគ្រប់ស្ថានីយ៍បោះឆ្នោតទាំងអស់ ។

លើសពីនេះ ជំនួយសម្រាប់អ្នកបោះឆ្នោត និងសន្លឹកឆ្នោតចម្លងជាភាសាពុនចាប ម៉ុង ចិន វៀតណាម កូរ៉េ ខ្មែរ និងភាសាតាកាឡុក គឺមាននៅតាមទីតាំងមណ្ឌលបោះឆ្នោតដែលបានកំណត់ក្នុងខោនធី Fresno ។ ចំពោះអ្នកបោះឆ្នោតដែលត្រូវការជំនួយ អាចនាំមនុស្សមកជាមួយបានរហូតដល់ពីរនាក់ ដើម្បីឲ្យពួកគេជួយអ្នកក្នុងការបោះឆ្នោតនៅទីតាំងបោះឆ្នោតតែម្តង ។ ចំពោះអ្នកបោះឆ្នោត ដែលបោះឆ្នោតតាមសំបុត្រ ដែលរស់នៅតាមមណ្ឌលបោះឆ្នោតរបស់ខ្លួន អាចហៅទូរស័ព្ទ ផ្ញើសំបុត្រ ផ្ញើទូរសារ ឬផ្ញើអ៊ីម៉េល មកកាន់មន្ត្រីបោះឆ្នោត ដើម្បីស្នើសុំសំណៅសន្លឹកឆ្នោតតាមទូរសារជាភាសាពុនចាប ម៉ុង ចិន វៀតណាម កូរ៉េ ខ្មែរ និងភាសាតាកឡុក តាមប្រៃសនីយ៍ ។ ការស្នើសុំសន្លឹកឆ្នោតខាងលើ ត្រូវផ្ញើមកឲ្យដល់ដៃមន្ត្រីបោះឆ្នោត មិនឲ្យយឺតជាង 7 ថ្ងៃ មុនការបោះឆ្នោតចូលមកដល់ ។ បញ្ជីឈ្មោះទីតាំងស្ថានីយ៍បោះឆ្នោតដែលបានកំណត់ និងជំនួយតាមភាសាណានិមួយៗ គឺមានបង្ហោះនៅឯ www.FresnoVote.com